ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ២៩ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ភ

មាតិកា

I - ឯកសាររបស់ព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៦-៧-១៩៩៦	ព្រះរាជក្រឹត្យ NS / RKT/0796/46 Accordant le rang de Sous Secrétaire d'État	១២៧៤

II - ទីស្ដីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

២៦-៨-១៩៩៦	អនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្ដីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតិអោយជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគចេញចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា	១២៧៥
០៥-៨-១៩៩៦	អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១២៧៩
០៥-៨-១៩៩៦	អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១២៨០
០៥-៨-១៩៩៦	អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១២៨២

២ - សេចក្ដីសំរេច

០៥-៨-១៩៩៦	សេចក្ដីសំរេចលេខ ៣១ សសរ ស្ដីពីការផ្ទេរសិទ្ធិ	១២៨៣
០៩-៨-១៩៩៦	សេចក្ដីសំរេចលេខ ៣១ សសរ ស្ដីពីការផ្ទេរសិទ្ធិ	១២៨៤

២

III - ភាគខាងបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០២-៨-១៩៩៦	ប្រកាសលេខ ២៤២/៩៦ ពម.បសទ.ប្រក អនុញ្ញាតជូនលោក ឆាយ ជុងហួន បើកអាជីវកម្មរោងពុម្ពឈ្មោះ « អាស្យាព្រីនធីញ អេនអាត់វីធីសមីនធ័ »	១២៨៥
០២-៨-១៩៩៦	ប្រកាសលេខ ២៤៣/៩៦ ពម.បសទ.ប្រក អនុញ្ញាតជូនលោក អ៊ីវ វ៉េង បើកអាជីវកម្មរោងពុម្ពឈ្មោះ « ខ្មែរអន្តរជាតិ »	១២៨៧
០៦-៨-១៩៩៦	ប្រកាសលេខ ២៤៧/៩៦ ពម.បល.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ	១២៨៨

២ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្ដីសំរេច

០៥-៨-១៩៩៦	សេចក្ដីសំរេចលេខ ៤៧១ សសរ.កសក ស្ដីពីការតែងតាំងមន្ត្រីជំនួយការលេខាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ	១២៩០

៣ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

០៥-៨-១៩៩៦	ប្រកាសលេខ ៦៧៧ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធមកជាសាលាបឋមសិក្សាពេញលក្ខណៈ	១២៩២
០៦-៨-១៩៩៦	ប្រកាសលេខ ៦៨០ អយក.ប្រក ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅជីវវិទ្យា សំរាប់សិស្ស « ថ្នាក់ទី ៧ »	១២៩៤

០៦-៨-១៩៩៦ ប្រកាសលេខ ៦៨១ អយក.ប្រក ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគីមីវិទ្យាសំរាប់សិស្ស « ថ្នាក់ទី ៧ » ១២៩៥

៤ - រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

០៨-៨-១៩៩៦ សេចក្ដីសំរេចលេខ ៤០៨ សសរ.មស.ក្រខ ស្ដីពីការបែងចែកសិស្ស និស្សិតចំនួន ១២ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស ១២៩៧

៥ - ទីស្ដីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ប្រកាស

០៧-៨-១៩៩៦ ប្រកាសលេខ ៧០៦ សកអ ស្ដីពីការលុបប្រកាសលេខ ១៤៦ សកអ ចុះថ្ងៃទី ១៥-២-១៩៩៦ ដែលស្ដីពីការអនុញ្ញាតអោយក្រុមហ៊ុន ឃីពហ្គោអ៊ីង (ហុងកុង) អ៊ិនវេស្ដមែន រៀបចំការងារបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ១២៩៩

៦ - ទីស្ដីការ ក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

០១-៨-១៩៩៦ សេចក្ដីសំរេចលេខ ១៤២/៩៦ កធស អនុញ្ញាតិជាគោលការណ៍អោយមានស្នាក់ការថ្វាយបង្គំនៃព្រះវិហារ « ក្រុមផ្សាយដំណឹងល្អរបស់កុមារកម្ពុជា CEF » ១៣០០

០១-៨-១៩៩៦ សេចក្ដីសំរេចលេខ១៤៣/៩៦ កធស អនុញ្ញាតិជាគោលការណ៍អោយមានស្នាក់ការថ្វាយបង្គំព្រះគ្រីស្ដនិកាយ សេវេនដេយ នៅភូមិទួលត្របែក ឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ១៣០២

០១-៨-១៩៨៦	សេចក្ដីសំរេចលេខ ១៤៤/៨៦ កផស ទទួលស្គាល់គណៈកម្មាធិការរបស់ក្រុមប្រឹក្សានៃ «ក្រុមជំនុំបេសកកម្មសេចក្ដីមេត្តាករុណានៃព្រះគ្រីស្ទ» ជាផ្លូវការ	១៣០៤
០៧-៨-១៩៨៦	ប្រកាសលេខ ១៤៧/៨៦ កផស.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ	១៣០៦
០៧-៨-១៩៨៦	សេចក្ដីសំរេចលេខ ១៤៩/៨៦ កផស អនុញ្ញាតិជាគោលការណ៍អោយមានស្នាក់ការថ្វាយបង្គំសាសនាគ្រីស្ទឈ្មោះ «ក្រុមជំនុំព្រះជាម្ចាស់ ដំណឹងល្អសព្វគ្រប់»	១៣០៨
០៧-៨-១៩៨៦	សេចក្ដីសំរេចលេខ ១៥០/៨៦ កផស អនុញ្ញាតិជាគោលការណ៍អោយមានវត្តឈ្មោះ តៃ ធៀង « ពុទ្ធសាសនា មហាយាន » នៅភូមិផ្សារលិច ឃុំព្រែកញ្ញៅ ស្រុកពញាឮ ខេត្តកណ្ដាល	១៣០៩

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

KRET

NS/KRT/0796/46

NOUS
NORODOM SIHANOUK
Roi du Cambodge

ACCORDONS

Le rang de Sous - Secrétaire d ' Etat à :

I /	S.Exc. Monsieur	OUM WEAKCHIRAVUTH
II/	S.Exc. Monsieur	DOUK CHENG KIM DIN
III/	S.Exc. Monsieur	CHEA PUNLOK
IV/	S.Exc. Monsieur	YOUK KUN
V/	S.Exc. Monsieur	SO SIDIM

ព្រះហស្ថលេខា
នរោត្តម សីហនុ

Fait en notre Royal Palais, à Phnom Penh,
le 16 Juillet 1996

II - និតិវិធីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ៣៧ អនក្រ.បក

អនុក្រឹត្យស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយ ជនបរទេសអន្តោប្រវេសន្ត ជាអ្នកវិនិយោគចេញ-ចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីអន្តោប្រវេសន៍

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

សំរេច

ជំពូកទី១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះកំណត់អំពីបែបបទ សំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្តជាអ្នកវិនយោគចេញ-ចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមាន ចែងក្នុងមាត្រា ២៨ ជំពូកទី ៤ នៃ ច្បាប់ស្តីពីប្រវេសន្ត ។

ជំពូកទី ២

បែបបទក្នុងការសុំចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ : ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគដែលបានទទួលលិខិតអនុញ្ញាតអោយវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ពីស្ថាប័នមានសមត្ថកិច្ចកម្ពុជា មានបំណងចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំទិដ្ឋាការចូល ព្រះរាជាណាចក្រកម្ពុជា ដោយផ្ទាល់មកក្រសួងមហាផ្ទៃ ឬ តាមរយៈអាជ្ញាធរទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬ អាជ្ញាធរបរទេសណាមួយតំណាងអោយផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេសដោយ :

១– ត្រូវបំពេញបែបបទទិដ្ឋាការ

២– ត្រូវបង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬ ឯកសារធ្វើដំណើរណាមួយ ដែលមានតម្លៃ ស្មើគ្នា ដែលមាន សុពលភាពយ៉ាងតិច ៦ ខែ មុនថ្ងៃចូលព្រះរាជាណាចក្រកម្ពុជា ។

៣– ត្រូវផ្តល់រូបថត ៤ × ៦ ចំនួន៣ សន្លឹក ថតចំពីមុខគ្មានពាក់វ៉ែនតាខ្មៅ ដែលទើបនឹងថត មិនលើសពី ៦ ខែ ។

៤– ត្រូវផ្តល់វិញ្ញាបនប័ត្របញ្ជាក់សុខភាព ចំនួនមួយច្បាប់ ដែលចេញអោយដោយវេជ្ជបណ្ឌិត ទទួលស្គាល់ជាផ្លូវការបញ្ជាក់ពីស្ថានភាពសុខភាព ។ វិញ្ញាបនប័ត្រនេះ ត្រូវមានកាលបរិច្ឆេទមិនហួសពី ៣ ខែ

៥– ត្រូវផ្តល់លិខិតថ្កោលទោសដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេស ដើមរបស់ខ្លួន ឬ លិខិតបញ្ជាក់ណាមួយដែលមានតម្លៃដូចគ្នា ។

៦– ត្រូវបង់អាករទិដ្ឋាការចំនួនពីរសែនប្រាំម៉ឺនរៀល (២៥០.០០០៖០០) ។

មាត្រា ... សមាជិកគ្រួសារផ្ទាល់ខ្លួនរបស់ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគ គឺ ប្តី ឬ ប្រពន្ធ កូនៗនៅលីវស្ថិតនៅក្នុងបន្ទុក ឪពុក ម្តាយបង្កើត និពុក ម្តាយក្មេកស្ថិតនៅក្នុងបន្ទុក និង អ្នកស្ថិតក្នុងបន្ទុកគ្រប់ប្រភេទ ត្រូវបំពេញបែបបទដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ។ កុមារមានអាយុ ១២ឆ្នាំចុះមិនបាច់បំពេញបែបបទទិដ្ឋាការដោយឡែកទេ តែត្រូវចុះឈ្មោះ និងបិទរូបថតរួមជាមួយឪពុក ម្តាយ ឬអាណាព្យាបាលប៉ុណ្ណោះ ប៉ុន្តែត្រូវបង់អាករ ទិដ្ឋាការ ចំនួន មួយសែនពីរម៉ឺនប្រាំពាន់រៀល (១២៥.០០០៖០០) ក្នុងម្នាក់ ។

មាត្រា ៤ : ការទទួលស្គាល់ជនបរទេសណាមួយថាជាជនបរទេសអន្តោប្រវេសន្ត ជាអ្នកវិនិយោគ ត្រូវ សំរេចដោយប្រកាសរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៥ : អាករទិដ្ឋាការគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។ បែបបទនៃការប្រមូលអាករទិដ្ឋាការនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

ជំពូកទី៣

ការស្នាក់នៅ

មាត្រា ៦ : ជនបរទេសដែលបានទទួលលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគព្រមទាំងគ្រួសារផ្ទាល់អាចស្នាក់នៅជាអចិន្ត្រៃយ៍ឬតាមរយៈពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតអោយវិនិយោគ ក្នុងព្រះរាជាណាចក្រកម្ពុជាបន្ទាប់ពីបានទទួលប័ណ្ណស្នាក់នៅចេញអោយដោយក្រសួងមហាផ្ទៃ ។

ជំពូកទី ៤

ការដកហូតលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគ

មាត្រា ៧ : អាចត្រូវដកហូតលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគ ដោយ ប្រកាសរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ចំពោះជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគណាដែលបានប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយដែល ត្រូវតុលាការផ្តន្ទាទោស ចាប់ពីបទឧក្រិដ្ឋឡើងទៅ ។

ជំពូកទី ៥

អវសានបញ្ញត្តិ

មាត្រា ៨ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៤១ អនក្រ.តក
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តរតនគីរី

សម្រេច

ប្រការ ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនចំពោះ ឯកឧត្តម **PAUL REDDICLIFFE** ឯកអគ្គរាជទូតអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ជំនួយជាប្រាក់ចំនួន ១១.០០០ ដុល្លារសហរដ្ឋអាមេរិក សំរាប់សាងសង់មណ្ឌលសុខភាព ស្រុកតាវែង ខេត្តរតនគិរី ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអភិបាលខេត្ត រតនគិរី ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៤២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើត និងប្រើប្រាស់មេដាយ ស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង អភិបាលខេត្ត មណ្ឌលគិរី ។

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនចំពោះសប្បុរសជន សញ្ជាតិអាល្លឺម៉ង់ ដែលបាន ជួយកសាងអាគារសិក្សា គិលានដ្ឋាន និងកីឡាដ្ឋាន នៅក្នុង ខេត្ត មណ្ឌលគិរី អស់ទឹក ប្រាក់១៤៣.០០០ដុល្លារសហរដ្ឋអាមេរិក ដូចមានរាយនាមតាមលំដាប់ថ្នាក់ខាងក្រោម ÷

១-ជូនមេដាយមាស ស្ថាបនាជាតិ ចំពោះលោក Carl Heinz Barrtels

២-ជូនមេដាយប្រាក់ ស្ថាបនាជាតិ ចំពោះឯកឧត្តម Dr. Wiprecht Von Treskow

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ និងអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ដលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៤៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត /១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិជូនលោក CHIO HO-CHEONG ប្រធានក្រុមហ៊ុន ANG-DU INTERNATIONAL CORPORATION LTD and FAR EAST (THAILAND) GROUP ដែលបានផ្តល់អំណោយជារថយន្ត MINI BUS ចំនួន ០៦ គ្រឿង មានតម្លៃ ២៤០.០០០ ដុល្លារសហរដ្ឋអាមេរិក ជូនដល់កងយោធពលខេមរភូមិន្ទ និង យុទ្ធជន ពិការ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងនាយកអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យ

នេះអោយទទួល បានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសម្រេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសម្រេចលេខ : ៣១ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ខាវ ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសឯកឧត្តម **គាត ឈន់** ដែលត្រូវ

អញ្ជើញទៅបំពេញបេសកកម្មនៅ បរទេស ចាប់ពីថ្ងៃទី ២៦ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **ជា ចាន់តូ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ : ៣២ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជ
- បានឃើញព្រះរាក្រឹត្យលេខ នស.រកត .១០៩៤ /៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់ក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ហូ សុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងមហាផ្ទៃ ជំនួសឯកឧត្តម **យូ ហុកគ្រី** ដែលបានច្បាប់ឈប់សំរាក ព្យាបាលជម្ងឺ ចាប់ពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ហូ សុខ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៤២/៩៦ ពម.បសឧ.ប្រក

អនុញ្ញាតជូនលោក ឆាយ ជុងហួន បើកអាជីវកម្មរោងពុម្ពឈ្មោះ

« អាសយ្យាព្រីនធីញ អេនអាត់ឌីធីសមីនធ័ »

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣-០៧-១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ
- តាមសំណើរបស់លេខាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ច ការព្រៃឈើ

សម្រេច

ប្រការ ១ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ៩ រូប ជាជំនួយការរដ្ឋលេខាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ដែលមានឈ្មោះដូចខាងក្រោម ÷

១-លោក **សេង គឹមស៊ុន**		មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់
២-លោក **ឌី សំអាន**		មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់
៣-លោក **ទឹម ស៊ុំ**		- ដ -
៤-លោក **ចាន់ រិទ្ធី**		- ដ -
៥-លោក **ហុង ណារិត**		- ដ -
៦-លោក **ហង់ ស៊ុនត្រា**		- ដ -
៧-លោក **ម៉ុច ឆុច**		- ដ -
៨-លោក **សេង ស៊ុនណារុន**		- ដ -
៩-អ្នកស្រី **ទៀប សុនិត**		- ដ -

២-អ្នកស្រី យាន ផាន់នារ៉ា អនុប្រធានការិយាល័យរៀប

៣-លោក ម៉ុក សារ៉ាត់ អនុប្រធានការិយាល័យបែងចែកពត៌មាន និងសន្និសិទ

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ , លោកនាយកខុទ្ទកាល័យ , លោកប្រធាន នាយកដ្ឋានមណ្ឌលពត៌មាន , លោកប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិក , លោកប្រធាន នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ និង អស់លោកក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ឡេង ម៉ុលធី

* * *

២ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៤៧៦ សសរ.កសក

ស្តីពី

ការតែងតាំងមន្ត្រីជំនួយការលេខាធិការប្រតិបត្តិ

នៃគណៈកម្មាធិការជាតិរៀបចំ និង អនុវត្ត

នយោបាយកិច្ចការព្រៃឈើ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មាន លេខ ១២២៤/៩៤ .ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ ASIA PRINTING & ADVERTISMMENT (អាស្យាព្រីនធីញ អេនអាត់វឺធីសមីនធ៍) របស់លោក ឆយ ជុងហ្គួន ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

សម្រេច

ប្រការ ១ : អនុញ្ញាតជូនលោក **ឆាយ ជុងហ្គួន** អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១០៤ អ៊ីអូមហាវិថី សុធារស សង្កាត់ ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ (អាស្យាព្រីនធីញ អេនអាត់វិធីសមីនធ៍) ទីតាំងស្ថិតនៅដូចលំនៅខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៤៣/៩៦ ពម.បសឧ.ប្រក

អនុញ្ញាតជូនលោក អ៊ឹម វែង បើកអាជីវកម្មរោងពុម្ពឈ្មោះ « ខ្មែរអន្តរជាតិ »

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន ។
- យោងលិខិតជូនដំណឹងរបស់ក្រសួងពតិមានលេខ ១២២៤/៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ « ខ្មែរអន្តរជាតិ » របស់លោក អ៊ឹវ វែង ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៦។

សម្រេច

ប្រការ ១ : អនុញ្ញាតជូនលោក **អ៊ឹម វែង** អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២១ អឺអូ ផ្លូវលេខ ១៦៣ ក្រុមទី ៨៣ សង្កាត់ វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « ខ្មែរអនន្តរជាតិ » ទីតាំងស្ថិតនៅផ្ទះលេខ ៣៤ អឺអូ ផ្លូវលេខ ១១៣ ក្រុមទី ៨ សង្កាត់បឹងព្រលិត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ អាស័យដ្ឋានទំនាក់ទំនងផ្ទះលេខ ២១ អឺអូ ផ្លូវលេខ ១៦៣ ក្រុមទី ៨៣ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹងទំនៀម ទំលាប់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៤៧/៩៦ ពម.បល.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

- បានឃើញព្រះរាជក្រម នសរកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- តាមការចាំបាច់របស់ក្រសួងពត៌មាន ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ ។

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ១០ រូប ជាអនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និង អនុប្រធានការិយាល័យ នាយកដ្ឋានមណ្ឌលពត៌មាន នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោមនេះ ÷

ក. ថ្នាក់អនុប្រធាននាយកដ្ឋាន :

១-អ្នកស្រី **តិន ចំនួដា** ទទួលខុសត្រូវការិយាល័យប្រមូលបែងចែកពត៌មាន និងការិយាល័យប្រភព ដំណឹង

២-លោក **កែវ ផន** ទទួលខុសត្រូវការិយាល័យពិនិត្យប្រព័ន្ធផ្សព្វផ្សាយ និង ការិយាល័យសំរបសំរួល ប្រព័ន្ធផ្សព្វផ្សាយ

ខ. ថ្នាក់ប្រធានការិយាល័យ :

១-លោក **លឹម សុខឃាន់** ប្រធានការិយាល័យរបៀប

២-លោក **ហ៊ុន ធីរៈ** ប្រធានការិយាល័យពិនិត្យប្រព័ន្ធផ្សព្វផ្សាយ

៣-លោក **ឡាំ សារន** ប្រធានការិយាល័យសំរបសំរួលប្រព័ន្ធផ្សព្វផ្សាយ

៤-លោក **មាស គឹមសួន** ប្រធានការិយាល័យប្រភពដំណឹង

៥-លោក **ស្រេង សារិន** ប្រធានការិយាល័យបែងចែកពត៌មាន និង សន្និសិទ

គ. ថ្នាក់អនុប្រធានការិយាល័យ :

១-លោក **គង់ សុផាត** អនុប្រធានការិយាល័យរបៀប

២-អ្នកស្រី យាន ផាន់ផា   អនុប្រធានការិយាល័យរៀប

៣-លោក ម៉ុក អាត់   អនុប្រធានការិយាល័យបែងចែកពត៌មាន និងសន្និសិទ

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ , លោកនាយកខុទ្ទកាល័យ , លោកប្រធាន នាយកដ្ឋានមណ្ឌលពត៌មាន , លោកប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិក , លោកប្រធាន នាយកដ្ឋានផែនការ គណនេយ្យហិរញ្ញវត្ថុ និង អស់លោកក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

[illegible]

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសម្រេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៤៧១ សសរ.កសក

ស្តីពី

ការតែងតាំងមន្ត្រីជំនួយការលេខាធិការប្រតិបត្តិ

នៃគណៈកម្មាធិការជាតិរៀបចំ និង អនុវត្ត

នយោបាយកិច្ចការព្រៃឈើ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣-០៧-១៩៩៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ
- តាមសំណើរបស់លេខាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ច ការព្រៃឈើ

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ៩ រូប ជាជំនួយការរដ្ឋលេខាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ដែលមានឈ្មោះដូចខាងក្រោម ÷

១-លោក **សេង គីមស៊ុន** មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់
២-លោក **ជា សំអាង** មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់
៣-លោក **គីម ស៊ីនូ** - ដ -
៤-លោក **ចាន់ រិទ្ធី** - ដ -
៥-លោក **ហុង ណារិត** - ដ -
៦-លោក **ហង់ ស៊ុនត្រា** - ដ -
៧-លោក **ម៉ិច ឆុច** - ដ -
៨-លោក **សេង ស៊ុនណារុន** - ដ -
៩-អ្នកស្រី **ឡៀប សុនិត** - ដ -

ប្រការ ២ : មន្ត្រីជំនួយការលេខាធិការប្រតិបត្តិ ត្រូវបំពេញការងារតាមការណែនាំរបស់លេខាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ។

ប្រការ ៣ : អគ្គនាយក ប្រធានមន្ទីរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ និងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សែនហួរ

* * *

៣ - លិខិតរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាស លេខ ៦៧៧ អយក.ប្រក

ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤

- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ ច ចុះថ្ងៃទី ២០-១១-៨៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-៨៦ ស្ដីពីការកំណត់បទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា
- បានពិនិត្យ លិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យលេខ ៦១ អយក ខ. ចទម ចុះថ្ងៃទី ០២ មករា ១៩៩៦
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ ផ្លាស់ :

១-សាលាឧបសម្ព័ន្ធក្បាលក្របី ពីសាលាបឋមសិក្សាបន្ទាយឆ្មារ មកជាសាលាបឋសិក្សាក្បាលក្របី ពេញលក្ខណៈ

២-សាលាឧបសម្ព័ន្ធថ្មដែកកេះ ពីសាលាបឋមសិក្សាបន្ទាយឆ្មារ មកជាសាលាបឋមសិក្សាថ្មដែក កេះ ពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ៩៥-៩៦ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ដូចមានរាយនាមខាងលើ ត្រូវដឹកនាំដោយ នាយកបង្រៀន ១ រូប ស្របតាមបទដ្ឋាន ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយកមានសិទ្ធិបើកប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន ផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បន្ទាយមានជ័យ ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុកថ្មពួក នាយកសាលាបឋមសិក្សាបន្ទាយឆ្មារ នាយកសាលាបឋមសិក្សាក្បាលក្របី នាយកសាលា

បឋមសិក្សាថ្មីដែកគេះ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាស លេខ ៦៨០ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅជីវវិទ្យាសំរាប់សិស្ស

« ថ្នាក់ទី ៧ »

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃ ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ ។
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅជីវវិទ្យា សំរាប់សិស្ស ថ្នាក់ទី៧ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅជីវវិទ្យាសំរាប់សិស្សថ្នាក់ទី៧ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការ ជីវវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជន និងកីឡា រៀបរៀងដោយអ្នកស្រី **ឆាន សោភ័ណ** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្ត សេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាស លេខ ៦៨១ អយក.ប្រក

ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគីមីវិទ្យា

សំរាប់សិស្ស « ថ្នាក់ទី ៧ »

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែ សំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទទ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅ គីមីវិទ្យាសំរាប់សិស្សថ្នាក់ទី ៧ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅគីមីវិទ្យាសំរាប់សិស្ស ថ្នាក់ទី ៧ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការគីមីវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជន និងកីឡា រៀបរៀងដោយលោក **ស៊ុន ប៊ុណ្ណា** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចអោយ មានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៤ - រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្ដីសំរេច លេខ ៤០៨ សសរ.មយ.ក្រខ

ស្ដីពីការបែងចែកសិស្ស និស្សិត ចំនួន ១២ នាក់

ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតលេខ ៣១៩ សជណ.ផកចុះថ្ងៃទី ២៨ ខែ ០២ ១៩៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រគីមី១ ចំនួន០១ នាក់ អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ១០ នាក់ និងអ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០១ នាក់ ដែលបានបញ្ចប់ការសិក្សាពីក្រៅប្រទេស ត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមក្រសួង ស្ថាប័នមួយចំនួនដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្ដីសំរេចនេះ ។

ប្រការ ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះដើម្បីរៀបចំការងារ អោយត្រូវតាមមុខជំនាញ និងផ្ដល់បៀវត្សជូន សាមីជនចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្ដីសម្រេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៧ខែ សីហា ឆ្នាំ ១៩៩៦

តារាងឧបសម្ព័ន្ធ នៃសេចក្ដីសម្រេចលេខ ៤០៨ សសរ មស.ក្រខ
ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៦ ស្ដីពីការបែងចែកសិស្ស និស្សិត
ចំនួន ១២ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

ល.រ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំ កំណើត	អង្គភាព ដើម	មុខជំនាញបច្ចេកទេស	បៀវត្ស	ប្រភព បណ្ដុះ បណ្ដាល
	១ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០៣ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់ឧត្ដម ០៣ នាក់						
១	ឡាយ ចុំច	ប	០៦-០៦-៧០	សិស្ស	សេ.កិ.ព្រៃឈើ	៩០ ខ.I.១	២
២	ឆាយ សុវណ្ណវត្តិទី	-	២៥-០៥-៧១	-	-	-	-
៣	ម៉ា ច័ន្ទពុត្ថា	-	៣០-០៤-៦៧	-	-	-	-
	២ - ក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ០១ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់មធ្យម ចំនួន ០១ នាក់						
៤	យិន គីមហុង	ប	១៥-០៨-៧៤	សិស្ស	សំណង់ស៊ីវិល + ឧ.កម្ម	៩០ ខ.II.១	១
	៣ - រដ្ឋលេខាធិការមុខងារសាធារណៈ ចំនួន ០១ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ០១ នាក់						
៥	ចាប ឌីណា	ប	២០-០៣-៧២	សិស្ស	ពត៌មានវិទ្យា	៩០ ខ.I.១	២
	៤ - ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ០១ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ០១ នាក់						
៦	ស្រ៊ុន ឃាង	ប	០៨-០៥-៦៩	សិស្ស	បច្ចេកវិទ្យាអេឡិចត្រូនិច និងទូរគមនាគមន៍	៩០ ខ.I.១	២
	៥ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រកិត ១ ចំនួន ០១ នាក់						
៧	អ៊ុក សារ៉ាវុធ	ប	១៤-០៦-៦២	មន្ត្រី ក.ជ.ក	វិទ្យាសាស្ត្រសេដ្ឋកិច្ច	[illegible] ខ.I.៤	១

ខ - អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០១ នាក់

៨	[illegible]	[illegible]	ប	០៤-០១-៦៩	សិស្ស	គ្រប់គ្រងសេដ្ឋកិច្ចជាតិ	៩០	[illegible]	១

៦ - ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចំនួន ០៤ នាក់

ក - អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០៤ នាក់

៩	សំ	[illegible]	ប	១១-០៥-៧[illegible]	សិស្ស	បច្ចេកវិទ្យាប្រេង	៩០	ខ.I ១	២
១០	[illegible]	[illegible]	-	២៣-០៣-៧១	-	-		-	-
១១	[illegible]	[illegible]		១៥-១០-៧២	-	-		-	-
១២	អ៊ុំ	[illegible]	-	១៥-០៣-៧១	-	ម្ហូបអាហារកំប៉ុង		-	

៥ - ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៧ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧០៦ សករ

ស្តីពីការលុបប្រកាសលេខ ១៤៦ សករ ចុះថ្ងៃទី ១៥-០២-១៩៩៦

ដែលស្តីពីការអនុញ្ញាតអោយក្រុមហ៊ុនឃីពហ្គោអ៊ីង (ហុងកុង)

រៀបចំវេស្តមែនជ្រើសរើសការងារបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាម ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៥៧ អនក្រ ប.ក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរ ទៅធ្វើការ

នៅបរទេស

- បានឃើញប្រកាសលេខ ១៤៦ សកអ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការអនុញ្ញាត អោយក្រុមហ៊ុនឃីពហ្គោអ៊ីង (ហុងកុង) អ៊ិនវេស្តមែន រៀបចំការងារបញ្ជូនពលករខ្មែរទៅធ្វើការ នៅបរទេស ។

សំរេច

ប្រការ ១ : លុបជាស្ថាពរនូវប្រកាសលេខ ១៤៦ សកអ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ១៩៩៦ ដែលស្តីពីការ អនុញ្ញាតអោយក្រុមហ៊ុនឃីពហ្គោអ៊ីង (ហុងកុង)អ៊ិនវេស្តមែន រៀបចំការងារបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ដោយក្រុមហ៊ុននេះមិនបានអនុវត្តតាមអនុក្រឹត្យលេខ ៥៧ អនក្រ ប.ក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ត្រង់មាត្រា ៧ ដែលចែងអំពីកាតព្វកិច្ចនៃការតំកល់ប្រាក់ធានា ។

ប្រការ ២ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

ស៊ុយ សែម

* * *

៦ - ទីស្តីការក្រសួងធម្មការ និង សាសនា

រាជធានីភ្នំពេញ .ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៤២/៩៦ ក.ធ.ស

អនុញ្ញាតែដគេលការណ៍អោយមានស្នាក់ការថ្វាយបង្គំនៃព្រះវិហារ

« ក្រុមផ្សាយដំណឹងល្អរបស់កុមារកម្ពុជា CEF »

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម-០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការថ្វាយបង្គំនៃវិហារក្រុមផ្សាយដំណឹងល្អរបស់កុមារកម្ពុជា C.E.F រាជធានីភ្នំពេញ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតិជាគោលការណ៍ អោយមានស្នាក់ការថ្វាយបង្គំនៃព្រះវិហារ « ក្រុមផ្សាយដំណឹងល្អ របស់កុមារកម្ពុជា C.E.F » មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៨៤ ផ្លូវលេខ ៤៥៤ សង្កាត់ទួលទំពូងទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះនៃវិហារ « ក្រុមផ្សាយដំណឹងល្អរបស់កុមារកម្ពុជា C.E.F » ត្រូវអនុញ្ញាតិអោយផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រីស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : គ្រប់បរិស័ទគ្រីស្តទាំងអស់ នៃស្នាក់ការវិហារ « ក្រុមផ្សាយដំណឹងល្អរបស់កុមារកម្ពុជា C.E.F »ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា ។ ស្នាក់ការ «ក្រុមផ្សាយដំណឹងល្អរបស់កុមារកម្ពុជា C.E.F » ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង រណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ .ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ១៤៣/៩៦ ក.ធ.ស

អនុញ្ញាតជាគោលការណ៍អោយមានស្លាក់ការថ្វាយបច្ច័

ព្រះត្រៃសុត្តនិកាយ សេទេនជេយ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម-០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤។

- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការថ្វាយបង្គំសាសនាគ្រីស្ទ និកាយសេវេន ដាយ អាត់វេនទីស្ទ ខេត្តស្វាយរៀង ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៦ ។

សម្រេច

ប្រការ ១ : អនុញ្ញាតិជាគោលការណ៍ អោយមានស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយ សេវេនដេយ អាត់វេនទីស្ទ មួយកន្លែងដែលមានទីតាំងស្ថិត នៅភូមិ ទួលត្របែក ឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

ប្រការ ២ : ព្រះវិហារ « ទួលត្របែក » ត្រូវអនុញ្ញាតិអោយផ្សព្វផ្សាយនូវរាល់ឯកសារ ផ្សេង ៗ របស់សាសនាគ្រីស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទគ្រីស្ទទាំងអស់នៃព្រះវិហារ « ទួលត្របែក » ត្រូវគោរពអោយបាន ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ ក្រសួងធម្មការ និង សាសនា ។ ព្រះវិហារ « ទួលត្របែក » ត្រូវមានទំនាក់ ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្សាដាច់ខាត មិនធ្វើអោយ ប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀប រយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង និង មន្ត្រី រាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តី សំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សោ ឡឺន ឆន្ទ្ធារិទ្ធ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៥៤/៩៦ ក.ធ.ស

ទទួលស្គាល់គណៈកម្មាធិការរបស់ក្រុមប្រឹក្សានៃ

« ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃ ព្រះគ្រីស្ត »

ជាផ្លូវការ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម-០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា ។
- បានឃើញសំណើសុំទទួលស្គាល់ក្រុមប្រឹក្សាដែលមានឈ្មោះថា «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃ ព្រះគ្រីស្ត » ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : ទទួលស្គាល់គណៈកម្មាធិការរបស់ក្រុមប្រឹក្សានៃ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រីស្ត » ជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ស្នាក់ការរបស់ក្រុមប្រឹក្សានេះ មានទីតាំងស្ថិតនៅ ផ្ទះលេខ ១១៣ ផ្លូវ ១៣០ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ក្រុមប្រឹក្សានៃ « ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រីស្ត » ត្រូវគោរពតាមលក្ខន្តិកៈរបស់ខ្លួន ដែលមានឯកសារតំកល់ទុកនៅក្រសួងធម្មការ និង សាសនា រាល់ការកែប្រែលក្ខន្តិកៈថ្មី ត្រូវមានឯកភាពពីក្រសួងជាមុន ។

ប្រការ ៣ : ក្រុមប្រឹក្សានៃ « ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃ ព្រះគ្រីស្ត » ត្រូវសហការណ៍ និងត្រូវមានទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ ករណីមានការផ្លាស់ប្តូរសមាសភាពដឹកនាំត្រូវមានការជូនដំណឹងមកក្រសួង ។

ប្រការ ៤ : ក្រុមប្រឹក្សានៃ « ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រីស្ត » ត្រូវផ្ញើរបាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមជំនុំ មកក្រសួងរៀងរាល់ត្រីមាស ឆមាស និង ឆ្នាំ ។

ប្រការ ៥ : ក្រុមប្រឹក្សានៃ « ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រីស្ត » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេង ៗ របស់ក្រសួងធម្មការ និងសាសនា រក្សាអោយបានល្អនូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម ។

ប្រការ ៦ : រាល់ការអនុវត្តផ្ទុយពីសេចក្តីសំរេចខាងលើនេះត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៧ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៨ : សេចក្តីសំរេចនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៤៧/៩០ កធស.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រម លេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង ធម្មការ និង សាសនា ។
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញលិខិតស្នើសុំតែងតាំងមន្ត្រីរាជការ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សា ។
- អនុលោមតាមការងារចាំបាច់របស់ក្រសួង និង សមត្ថភាពមន្ត្រីរាជការ ។

សំរេច

ប្រការ ១ : តែងតាំង ÷

១-អ្នកស្រី **ជុន ជល្លា** បច្ចុប្បន្នជាអនុប្រធានការិយាល័យពុទ្ធិកបឋមសិក្សា តែងតាំងជាប្រធានការិយាល័យពុទ្ធិកបឋមសិក្សា ។

២–លោក អ៊ុំ វណ្ណៈ បច្ចុប្បន្នជាអនុប្រធានការិយាល័យពុទ្ធិកមធ្យមសិក្សាតែងតាំងជាប្រធានការិយាល័យពុទ្ធិកមធ្យមសិក្សា ។

៣–អ្នកស្រី សម យ៉ុន បច្ចុប្បន្នជាអនុប្រធានកាលិយាល័យគរុកោសល ទទួលបន្ទុកបណ្ណាល័យ តែងតាំងជាប្រធានការិយាល័យស្ថិតិ ។

៤–លោក យស់ លាង បច្ចុប្បន្នជាអនុប្រធានការិយាល័យធម្មវិន័យ តែងតាំងជាប្រធានការិយាល័យធម្មវិន័យ ។

៥–លោក ថ្នាំ អ៊ិន បច្ចុប្បន្នជាមន្ត្រីការិយាល័យពុទ្ធិកបឋមសិក្សា តែងតាំងជាអនុប្រធានការិយាល័យពុទ្ធិកបឋមសិក្សា ។

ប្រការ ២ : ខុទ្ទកាល័យ អគ្គាធិការដ្ឋានពុទ្ធិកសិក្សា នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច (ការិយាល័យបុគ្គលិក ការិយាល័យគណនេយ្យ) និងអស់លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការមួយ ត្រូវអនុវត្ត រៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៤៩/៩០ កធស.ប្រក

អនុញ្ញាតិជាគោលការណ៍អោយមានស្លាក់ការផ្សាយបង្កើតសាសនាគ្រីស្តឈ្មោះ

« ក្រុមជំនុំព្រះជាម្ចាស់ដំណឹងល្អសព្វគ្រប់ »

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រម លេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង ធម្មការ និង សាសនា ។
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បនឃើញពាក្យសុំបើកស្នាក់ការថ្វាយបង្គំគ្រីស្តឈ្មោះ « ក្រុមជំនុំព្រះជាម្ចាស់ដំណឹងល្អសព្វគ្រប់ » រាជធានីភ្នំពេញ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយមានស្នាក់ការថ្វាយបង្គំសាសនាគ្រីស្ត « ក្រុមជំនុំព្រះជាម្ចាស់ ដំណឹងល្អសព្វគ្រប់ » នៃ «ក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា » មួយកន្លែងដែលមានទីតាំងស្ថិតនៅក្រុមទី ០៩ ផ្លូវលេខ ៣២៤ សង្កាត់ បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំសាសនាគ្រីស្តឈ្មោះ « ក្រុមំនុំព្រះជាម្ចាស់ ដំណឹងល្អសព្វគ្រប់ » នៃ «ក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា » ត្រូវអនុញ្ញាតិអោយផ្សព្វផ្សាយ នូវរាល់ឯកសារផ្សេង ៗ របស់សាសនាគ្រីស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទគ្រីស្តទាំងអស់នៃស្នាក់ការថ្វាយបង្គំសាសនាគ្រីស្ត « ក្រុមជំនុំព្រះជាម្ចាស់ នៅកម្ពុជា » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណា

ចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេង ។ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំស្នាក់ការថ្វាយបង្គំសាសនាគ្រីស្ទនៃ « ក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា » ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៥០/៩០ កធស.ប្រក

អនុញ្ញាតិជាគោលការណ៍អោយមានវត្តឈ្មោះ តែ ធៀង

« ពុទ្ធសាសនា មហាយាន »

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញព្រះរាជក្រម លេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង ធម្មការ និង សាសនា ។
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៩៤។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកវត្តឈ្មោះ តៃ ធៀង ពុទ្ធសាសនាមហាយាន ខេត្តកណ្តាល ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតិជាគោលការណ៍អោយមានវត្តឈ្មោះ **តៃ ធៀង** « ពុទ្ធសាសនាមហាយាន » មួយកន្លែងដែលមានទីតាំងស្ថិតនៅក្រុមទី ៧ ភូមិផ្សារលិច ឃុំព្រែកពោធិ៍ ស្រុកពញាឮ ខេត្តកណ្តាល ។

ប្រការ ២ : វត្តឈ្មោះ **តៃ ធៀង** « ពុទ្ធសាសនា មហាយាន » ត្រូវអនុញ្ញាតិអោយផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់ព្រះពុទ្ធសាសនា មហាយាន ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃវត្ត **តៃ ធៀង** « ពុទ្ធសាសនា មហាយាន » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំវត្ត « **តៃ ធៀង** » ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : ទាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនា ខេត្តកណ្តាល និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ៉េត្ន

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៦៩០ រៀល